# ស្វាគមន៍ដល់ការណែនាំដែមានប្រយោជន៍ដល់ភាពត្រឹមត្រូវតាមសីលធិម្មនការស្រាវជ្រាវ

វិធីជាច្រើនសំរាប់ស្រាវជ្រាវកំពុងផ្លាស់ប្ដូរគួរអោយភ្ញាក់ផ្អើល ។ការធ្វើការស្រាវជ្រាវធ្លាប់តែត្រូវបានគេចាត់ទុកជាសិទ្ធិរបស់អ្នក វិទ្យាសាស្ត្រប៉ុណ្ណោះ តែក្នុងបច្ចុប្បន្ននេះ ការស្រាវជ្រាវបានត្រូវគេឃើញមាននៅតាមពាណិជ្ជកម្មរបស់សហគមន៍ផងដែរ ។ មានការបង្កើន ការចេះដឹងមួយពីសារៈសំខាន់នៃការគោរពសិទ្ធិផ្សេងៗរបស់អ្នកចូលរួមមិនត្រឹមតែជាមនុស្សម្នាក់ៗទេ ថែមទាំងជាសមាជិកនៃសហគមន៍ ផងដែរ ដែលអាចត្រូវទទួលឥទ្ធិពលពីការស្រាវជ្រាវនេះ ។

ក្នុងពេលដែលសហគមន៍ជាច្រើនបានចូលប្រឡូកក្នុងការស្រាវជ្រាវកាន់តែខ្លាំងឡើង ទ្វេគ្រោះ( សភាពចុះទឹកក្រពើឡើងលើខ្លា) ពីសីលធិម បានត្រូវកើតមានឡើងនៅគ្រប់តំណាក់កាលក្នុងការស្រាវជ្រាវ ។ ទ្វេគ្រោះទាំងនេះរាប់បញ្ចូលទាំងសំណួរផ្សេងៗដូចជា អ្នកណា ជាអ្នកសំរេចថាតើរបៀបវារៈនៃការស្រាវជ្រាវមានអ្វីខ្លះ អ្នកណាដែលមានឥទ្ធិពលក្នុងការទំនាក់ទំនងនៃការស្រាវជ្រាវ តើភាពជាដៃគូ នឹងត្រូវរៀបចំឡើងដោយរបៀបណា ហើយវានឹងដំណើរការបានស្រួលឬយ៉ាងណា និងអ្នកណាជាម្ចាស់នៃទិន្នន័យ ។ បញ្ហាទាំងអស់នេះ ត្រូវការប្រកាសអោយគេបានស្ដាប់និងដឹងឮ ។

នៅសាកលវិទ្យាល័យ ឡូវែល ម៉ាស្សាឈូសេត (University of Massachusetts Lowell) ពួកយើងកំពុងធ្វើការយ៉ាង សស្រាក់សស្រាំ ដើម្បីបង្កើតការចូលរួមភាពជាដៃគូស្រាវជ្រាវរវាងសាកលវិទ្យាល័យហើយនិងសហគមន៍ដែលត្រូវគេផ្ដត់ផ្គង់សេវាកម្មមិន គ្រប់គ្រាន់ ។ ក្រដាស់ដ៏មានប្រយោជន៍ប៉ុន្មានសន្លឹកនេះ ដែលរួមបញ្ចូលក្នុងសៀវភៅក្បួនវិធីនេះ ត្រូវបានគេបង្កើតឡើងទុកជាផ្នែកមួយនៃ ការប្រជុំផ្លាស់ប្ដូរយោបល់ផ្សេងៗ ពីបញ្ហាសីលធិមក្នុងការស្រាវជ្រាវដែលផ្អែកលើភាពជាដៃគូ ។ យើងសង្ឃឹមថាក្រដាស់ដ៏មានប្រយោជន៍ ប៉ុន្មានសន្លឹកនេះ អាចជួយអ្នកបានក្នុងការដោះស្រាយបញ្ហាដែលទាក់ទងនឹងភាពត្រឹមត្រូវតាមសីលធិមខ្លះៗដែលផុសចេញនៅក្នុងភាពជា ដៃគូ ។ ប្រធានបទនៃក្រដាសដ៏មានប្រយោជន៍ នេះមាន:

- ការចាប់ផ្ដើមភាពជាដៃគូដំបូងគឺការប្រមូលអ្នកចូលរួមលេង
- សំនួរពីភាពជាដៃគូការស្រាវជ្រាវដំបូងក្នុងសហគមន៍
- មូលដ្ឋាននៃការស្រាវជ្រាវរកភាពជាដៃគូ: របៀបដែលសហគមន៍ថ្លឹងថ្លែងកម្លាំងក្នុងការស្រាវជ្រាវភាពជាដៃគូ
- អ្វីៗដែលអ្នកតែងតែចង់ដឹងពី IRB's
- ការពុះពារឧបសគ្គជាច្រើនដើម្បីទៅដល់ភាពជាដៃគូ
- កន្លែងតាំងគ្រឿងវិទ្យាសាស្ត្រនៅក្នុងទីក្រុងឡូវែល
- ការបង្កើតចំណេះដឹងក្នុងការស្រាវជ្រាវភាពជាដៃគូ

សូមមេត្តាប្រើក្បួនវិធីទាំងនេះទៅតាមបំណងរបស់អ្នកចុះ យើងខ្ញុំនឹងសប្បាយចិត្តកាន់តែខ្លាំងថែមទៀត ប្រសិនបើយើងខ្ញុំបាន ទទួលការឆ្លើយតបពីលោកអ្នកដើម្បីបន្ថែមគ្រឿងគ្រៅ ( យោបល់) ដើម្បីធ្វើអោយក្បួនវិធីទាំងនេះកាន់តែប្រសិទ្ធិភាពខ្លាំងថែមទៀត ។ បើសិនជាលោកអ្នកមានចំងល់ ឬសំណួរអ្វី សូមអញ្ជើញអ៊ីម៉េលទៅ Linda Silka (Linda_Silka@uml.edu, 978-943-4247). សូមអរគុណ!

# ការចាប់ផ្តើមភាពជាដៃគូដំបូងគឺការប្រមូលអ្នកចូលរួមលេង

**ដាស៊ី  បូយឺរ (Darcie Boyer)**

ដូចអ្នកបានដឹងមកហើយពីបញ្ហា ឬទីកន្លែងនៅក្នុងសហគមន៏ ដែលអ្នកជឿថា ជាការធានាអោយមានការសិក្សាបានវែងឆ្ងាយថែមទៀតនោះ អ្នកចង់បានការតបតខ្លះ ដើម្បីអោយដឹងថាតើ អ្នកដទៃទៀតក្នុងសហគមន៏ មានអារម្មណ៏ដូចគ្នាទេ ប៉ុន្តែអ្នកមិនប្រាកដថាគួរតែរកមើលនៅឯណា ឬក៏សួរអ្នកណាឡើយ ។ របៀបខាងក្រោមនេះអាចជួយអ្នកជាគំនិតក្នុងការចាប់ផ្តើមបង្កើតភាពជាដៃគូនេះបាន ។

<u>ដើម្បីបង្ហាញអោយយល់ពីដំណើរការនេះ  សូមអោយប្រើឧទាហរណ៍មួយនេះ។</u>

ឧបមាថាអ្នកបានសំគាល់ឃើញថាការប្រើប្រាស់កង់ ដែលបានធ្លាក់ចុះ ដែលគួរអោយចាប់អារម្មណ៏ក្នុងប៉ុន្មានឆ្នាំនេះ បង្កើតអោយមានបញ្ហាដល់សុខភាព ការជ្រើសរើសការធ្វើដំណើរ និងបញ្ហាបរិដ្ឋាន ។ តើអ្នកគួរតែបង្កើតភាពជាដៃគូយ៉ាងណា ដើម្បីរកអោយឃើញនូវមូលហេតុដែលបណ្តាលអោយការប្រើប្រាស់កង់បានធ្លាក់ចុះហើយរកឃើញដំណោះស្រាយដែលល្អ ឡើងវិញ?

ស្វែងយល់ពីមនុស្សឬអង្គការដែលត្រូវប៉ះទង្គិចដោយការសិក្សានេះឬក៏អ្នកណាដែលមានឥទ្ធិពលក្នុងសហគមន៏ ដូចជាអ្នកផ្តល់ការរក្សាសុខភាព សកម្មជនក្នុងសហគមន៏ ជនដែលគ្មានរថយន្តឬប័ណ្ណអនុញ្ញាតិ ក្រុមបរិដ្ឋាន អ្នករដ្ឋការក្នុងសាលា អ្នកគ្រោងផែនការក្រុងជាដើម ។ ចូរសួរខ្លួនឯងថា តើអ្នកណាជាអ្នកមានជំហរក្នុងការស្រាវជ្រាវនេះ?

ដើម្បីរកដៃគូស្រាវជ្រាវដែលមានលទ្ធភាពម្នាក់ អ្នកប្រហែលជាចង់រកមនុស្សម្នាក់ដែលមានវត្តមានល្អ ហើយត្រូវបានគេស្គាល់មុខមាត់ច្រើន នៅក្នុងសហគមន៏រួចហើយ បើសិនជាមិនអាចរកបានទេ អ្នកអាចចូលរកពិតមានពីសាកលវិទ្យាល័យក្នុងស្រុក និងស្វែងរកអ្នកស្រាវជ្រាវម្នាក់ ដែលបានធ្វើការក្នុងវិស័យនេះ ឬក៏អ្វីដែលទាក់ទងនឹងវិស័យនេះ ។

ឥឡូវនេះអ្នកមានបញ្ជីឈ្មោះនៃដៃគូដែលមានសមត្ថភាព បន្ទាប់មកគឺអញ្ជើញពួកគេមកដើម្បីចូលរួមជាដៃគូជាមួយអ្នកនិងអ្នកដទៃទៀតផង ។ ម្នាក់ៗមានវិធីនៃការប្រាស្រ័យទាក់ទងផ្សេងៗគ្នា អ្នកខ្លះចូលចិត្តប្រើទូរស័ព្ទ តែអ្នកខ្លះទៀត ចូលចិត្តការសរសេរសំបុត្រជាង ទោះជារបៀបនៃការទាក់ទងគ្នាដែលអ្នកចង់ធ្វើយ៉ាងម៉េចក៏ដោយក៏នៅមានពិតមានខ្លះៗទៀត ប្រហែលជាអ្នកចង់បញ្ចូល បន្ថែមទៀតផងដែរ ។

✧ ចូរណែនាំខ្លួនឯងដើម្បីអោយគេដឹងថាអ្នកជាអ្នកណាហើយហេតុអ្វីបានជាអ្នកមានចំណាប់អារម្មណ៏ក្នុងគំរោងការនេះ ។

**"ខ្ញុំឈ្មោះ Darcie Boyer រស់នៅ Lowell Highlands ។ ខ្ញុំចង់លើកទឹកចិត្តកូនខ្ញុំទាំងអស់អោយជិះកង់ទៅ សាលារៀន ហើយទៅលេងនៅសួនឧទ្យាន ប៉ុន្តែខ្ញុំបារម្ភអំពីសុវត្តិភាពរបស់ពួកគេ ។ ខ្ញុំចង់ស្វែងយល់អោយបានដឹងច្បាស់  ថាតើសហគមន៏យើងអាចប្រើរបៀបយ៉ាងណាទើប ដែលក្នុងពេលតែមួយអាចបង្កើនសុវត្តិភាព និង បង្កើនការប្រើប្រាស់កង់ នេះបាន" ។**

✧ ចូរផ្តល់បទពិសោធន៏ខ្លះៗអំពីការស្រាវជ្រាវនេះ បង្ហាញពួកគេថាអ្នកមានចំណាប់អារម្មណ៏យ៉ាងឈ្លាសវៃហើយថែមទាំងមានគំនិតយោបល់ពីបញ្ហានេះរួចហើយ ។ គន្លឹះគឺត្រូវផ្តល់ពិតមានអោយបានគ្រប់គ្រាន់ដល់ពួកគេ ដើម្បីអោយពួកគេចាប់ អារម្មណ៏ ប៉ុន្តែមិនត្រូវផ្តល់ពិតមានច្រើនពេកទេ អ្នកអាចធ្វើអោយគេធុញទ្រាន់ អ្នកមិនចង់អោយគេដឹងថាអ្នកមានចំលើយ ទៅបញ្ហាហ្នឹងរួច ហើយដែរទេ ។

✧ **"ខ្ញុំបានដឹងអំពីសហគមន៏ជាច្រើននៅក្នុងរដ្ឋអរីហ្គិន(Oregon) ដែលបានអនុវត្តន៏វិធានការដែលធ្វើអោយចរាចរណ៏បានស្ងប់ស្ងាត់ ហើយខ្ញុំជឿជាក់ថាពួកយើងអាចទទួលបានគំនិតដ៏មានតំលៃខ្លះៗពីបទពិសោធន៏ របស់ពួកគេ ប៉ុន្តែខ្ញុំក៏ចង់ដឹងអោយបាន**

**ច្បាស់ ថាផ្លូវដោះស្រាយនេះនឹងមានប្រសិទ្ធភាពសំរាប់សហគមន៏យើងដែរទេ ។ វាប្រហែលជាមានយុទ្ធសាស្ត្រផ្សេងទៀត ដែលយើងអាច ប្រើប្រាស់បាន នេះគឺជាអ្វីដែលខ្ញុំសង្ឃឹមថានឹងទទួលបានតាមរយៈភាពជាដៃគូនេះ" ។**

✧ ចូរទទួលស្គាល់ជំនាញរបស់ពួកគេ ជ្រើសយកឧទាហរណ៏នៃការងាររបស់គេពីមុនៗមក ហើយនិងពន្យល់ដោយលើកឧទាហរណ៏ ពីអ្វីដែលអ្នកគិតថាពួកគេផ្តល់អោយដល់ភាពជាដៃគូនេះ ។ ប្រាប់អោយពួកគេដឹងនូវអ្វីដែលអ្នកចង់បាន ពីពួកគេ ។

**"ទោះបីជាការបារម្ភដំបូងរបស់ខ្ញុំដែលទាក់ទងនឹងបញ្ហានេះ គឺជាសុវត្ថិភាពក៏ដោយ ខ្ញុំក៏នៅតែចាប់អារម្មណ៏នឹងប្រយោជន៏នៃបរិដ្ឋានដែលការប្រើប្រាស់កង់អោយបានកើនឡើងនេះដែរ ។ អ្នកបានធ្វើការងារដ៏អស្ចារ្យនៅក្នុងសហគមន៏ ដែល បានធ្វើអោយយើងដឹងច្បាស់ពីបញ្ហានៃការចោលសំរាម ហើយខ្ញុំមានអារម្មណ៏ថាបទពិសោធន៏ ទៅលើបញ្ហាបរិដ្ឋាន របស់ខ្ញុំអាចជាទ្រព្យដ៏សំខាន់មួយសំរាប់ភាពជាដៃគូរបស់យើង" ។**

✧ នេះប្រហែលជាមានប្រយោជន៏ក្នុងការបង្ហាញស្ថានការណ៏នេះទៅជាបញ្ហាមួយដើម្បីនាំមកនូវក្តីរំជួលចិត្ត ។ មានបញ្ហាជាច្រើនដែលត្រូវការដោះស្រាយ ហើយមនុស្សម្នាក់នេះមានគំនិតយោបល់ខ្លះៗដែលត្រូវការរួមបញ្ចូលគ្នា ។

**"ក្នុងចំណោមបញ្ហាពិបាកៗទាំងអស់ បញ្ហាមួយដែលខ្ញុំជួបប្រទះក្នុងភាពជាដៃគូនេះគឺការពន្យល់មនុស្សអោយផ្លាស់ប្តូរការយល់ឃើញរបស់ពួកគេថា ត្រូវតែផលិតកង់អោយបានច្រើនឡើងវិញ ។ ខ្ញុំជឿជាក់ថាជោគជ័យរបស់អ្នកក្នុងវិស័យកាត់បន្ថយការចំណាយអាចជួយភាពជាដៃគូនេះដោះស្រាយបញ្ហាកែប្រែប្រហែលជាអាចជួយភាពជាដៃគូនេះ ដោយបញ្ចុះបញ្ចូល គំនិតអោយមានការប្រើប្រាស់កង់នេះទៅសង្គមគេឥឡូវ ដែលកំពុងពេញនិយមក្នុងការប្រើប្រាស់ឡាន" ។**

✧ ចូររាយគោលបំណងរបស់សម្ព័ន្ធភាពនៃការស្រាវជ្រាវខ្លះៗដែលអាចសំរេចទៅបាន ដើម្បីពន្យល់ពីប្រយោជន៏នៃការចូលរួមជាក្រុមមួយ ។

**"ខ្ញុំសង្ឃឹមថាដោយសារភាពជាដៃគូរនេះ សហគមន៏យើងអាចបង្កើនការប្រើប្រាស់កង់ ហើយបន្ថយដំណើរស្ទះចរាចរណ៏ បង្កើនសុវត្ថិភាព និង ធ្វើអោយគុណភាពខ្យល់កាន់តែប្រសើរឡើង ។ យើងអាចសំរេចការនេះទៅបានគឺ ដោយសារការ យល់ដល់ជំរៅនៃការចូលរួមនៅក្នុងភាពជាដៃគូរនេះ" ។**

🚲 អ្នកបានធ្វើការដ៏អស្ចារ្យមួយដោយបានបង្កើតការចាប់អារម្មរណ៏ក្នុងគំរោងការស្រាវជ្រាវដែលមានបញ្ជីនៃក្រុមជាច្រើន ដែលបានចាប់អារម្មណ៏ ។ នេះប្រហែលជាគំនិតល្អមួយ បើយើងមានការប្រជុំតូចៗតាមតុមូលនិយាយពីចំនុចសំខាន់ទាំង នេះមុនពេលមានការប្រជុំធំក្នុងសហគមន៏ ។ នេះអាចជួយយើងអោយកំណត់គោលបំណងខ្លះៗបាន ហើយនិងធានាថាយើង អាចបញ្ជាក់ពីគំនិត និង បង្ហាញការចាប់អារម្មណ៏ផ្សេងៗទាំងអស់ក្នុងពេលប្រជុំ ។ នៅពេលដែលរៀបចំការប្រជុំនេះ ចូរ ព្យាយាមរកពេលវេលាណា ដែលសម ស្របសំរាប់អ្នករាល់គ្នា ហើយទីកន្លែងដែលមានបរិយាកាសល្អហើយផ្តល់ភាពកក់ក្តៅ និងងាយស្រួលផងដែរ ។

🚲 ប្រើការតបតដែលអ្នកបានទទួលពីការប្រជុំតុមូល ដើម្បីបង្កើតរបៀបវារៈមួយសំរាប់ការប្រជុំសហគមន៏ ។ អ្នកប្រហែលជាចង់ចែករំលែករបៀបវារៈនេះអោយទៅអ្នកផ្សេងទៀត ដែលបានចូលរូមការប្រជុំ ដើម្បីអោយពួកគេ មានឱកាស បញ្ចេញយោបល់ទៅលើមាតិការនេះ ។

🚲 ឥឡូវនេះអ្នកអាចយកគំរោងការទៅសហគមន៏ ។ នេះគឺពេលដែលយើងត្រូវឡើងជិះកង់ ។

# ការពិចារណាដែលត្រឹមត្រូវ តាមសីលធិមក្នុងការស្រាវជ្រាវ ដែលបានចូលរួម

មតិរបស់អ្នកស្រាវជ្រាវ

**ម៉ារីយ៉ាន ខូស្ទេឡូ (Maryjane Costello)**

បញ្ហាសំខាន់មួយនៃបញ្ហាសំខាន់ៗជាច្រើន តែមិនមែនជាបញ្ហាសំខាន់បំផុតមួយ ដែលជនម្នាក់ៗ និងក្រុមផ្សេងៗបានចុះប្រឡូក ប្រឈមមុខដោះស្រាយនឹងភាពជាដៃគូ ដែលមានមូលដ្ឋានក្នុងសហគមន៏ នោះគឺអំណាច ។ ក្នុងទំនាក់ទំនងណាមួយក៏ដោយ ជនណាដែល មានអំណាច កំនត់ថាតើ អ្នកណា វិធីណា ជាអ្វី ហើយនិងហេតុអ្វី បានជាមូលហេតុប្រាកដមួយនេះត្រូវបានគេជ្រើសរើសនិងធ្វើតាម ។ ក្នុង ទំនាក់ទំនងនៃភាពជាដៃគូស្រាវជ្រាវមួយ អំណាចត្រូវបានបង្ហាញអោយឃើញដោយការឃុំគ្រង គឺថាតើអ្នកណាគ្រប់គ្រងអ្វីដែលត្រូវស្រាវ ជ្រាវ ហេតុអ្វីត្រូវស្រាវជ្រាវពីវា ហើយតើត្រូវស្រាវជ្រាវយ៉ាងណា និងលទ្ធផលនៃការស្រាវជ្រាវ ។ យើងត្រូវដឹងថាមនុស្សម្នាក់ៗដែលចូលរួមក្នុងភាពជាដៃគូអាចប្រើប្រាស់ប្រភពនៃអំណាចមួយបាន គឺថាវាជាការក្តោបក្តាប់ផ្នែកដែលទាក់ទងនឹងទំនៀមទំលាប់ និងមូលដ្ឋានចំណេះដឹងនៃអ្នកស្រាវជ្រាវ ឬក៏ការរុករកប្រើប្រាស់ និងការយល់ដឹងពីមនុស្ស ប្រពៃណី និងវប្បធិមរបស់អ្នកចូលរួមក្នុងសហគមន៏ ។

ដើម្បីធានាថាបញ្ហានៃអំណាចដែលត្រូវបានប្រគល់ដោយយុត្តិធិមក្នុងភាពជាដៃគូស្រាវជ្រាវ អ្នកចូលរួមក្នុងភាពជាដៃគូស្រាវជ្រាវដែលមានមូលដ្ឋានក្នុងសហគមន៏ម្នាក់ៗ ត្រូវវាងវៃឆាប់យល់ចុងដើមពីការពិចារណាដ៏ត្រឹមត្រូវដែលកំនត់ពីរបៀបដែលគំរោងការនេះ ត្រូវបានគេរៀបចំ និងអនុវត្តន៏ ។

ពេលដែលយើងម្នាក់ៗប្រហែលជាមានអារម្មណ៏ជឿជាក់ថា យើងយល់ពីកាតព្វកិច្ច និងការទទួលខុសត្រូវលើឥរិយាបទដែលត្រឹម ត្រូវ យើងប្រហែលជាមិនជឿជាក់ទេ ប្រសិនបើគេសុំអោយយើងកំនត់ និងពន្យល់ពាក្យ"សីលធិម" ។ ដើម្បីបកប្រែអត្ថន័យ នៃការសំរេច ចិត្តរបស់តុលាការលើសៀវភៅសរសេរ ឬរូបភាពអាសអាភាស យើងប្រហែលជាមិនអាចកំនត់ពាក្យសីលធិមបានទេ ប៉ុន្តែយើងដឹងថាវា នឹងដូចអ្វី នៅពេលដែលយើងឃើញវា ។ ក្នុងសៀវភៅវចនានុក្រុមទំនើបអក់ស្វាត (Oxford Modern Dictionary) សីលធិមត្រូវបាន គេអោយអត្ថន័យថាជាប្រព័ន្ធមួយនៃគោលការណ៏ដឹងខុសដឹងត្រូវ អត្ថន័យគឺមិនច្បាស់លាស់គ្រប់គ្រាន់សំរាប់ប្រើប្រាស់នៅឡើយ ។ វាអាចជួយក្នុងការបំបែកគំនិតនៃសីលធិមទៅជាឃ្លានិងពាក្យសំខាន់ៗ ដូចជា"បណ្តាលអោយគ្មានគ្រោះអ្វី" "កង្វល់ពីគំរូនៃមាយាទទូទៅ" ភាព សមរម្យ ភាពយុត្តិធិម សេចក្តីគោរព ឬក៏ភាពថ្លៃថ្នូរ ។

យើងរាល់គ្នាប្រហែលឆ្លើយតបទៅ "គន្លឹះសីលធិម" ផ្សេងៗដោយផ្អែកលើប្រវត្តិ និងបទពិសោធន៏ផ្ទាល់ខ្លួនរបស់យើង ។ ប្រសិន បើខ្ញុំជាមនុស្សចាស់ដែលគ្មានលំនៅម្នាក់ ភាពថ្លៃថ្នូរអាចផ្តល់នូវមូលដ្ឋាននៃគំនិតត្រឹមត្រូវតាមសីលធិមរបស់ខ្ញុំ តែប្រសិនបើខ្ញុំជាស្ត្រីម្នាក់ ក្តីយុត្តិធិមអាចផ្តល់នូវការភ្ជាប់ដ៏ត្រឹមត្រូវទៅនឹងទស្សនៈរបស់ខ្ញុំចំពោះពិភពលោកទាំងមូល ។ យើងទាំងអស់គ្នាត្រូវតែវាងវៃឆាប់ដឹងពី ការពិតដែលថា នៅពេលដែលយើងធ្វើការជាមួយបញ្ហាផ្សេងៗនៃសីលធិម យើងត្រូវធ្វើជាគំរូដ៏ល្អបំផុតនៃការបត់បែន ដែលបន្តការទទួល គំនិតថ្មីៗ និងការស្ម័គ្រចិត្តចង់ស្តាប់យោបល់របស់អ្នកចូលរួមគ្រប់គ្នា ។

ប៉ុន្តែបន្ថែមពីលើការយល់ដឹងពីរបៀបដែលយើងកំនត់ន័យនៃសីលធិមដែលមានជាប់ជានិច្ចក្នុងគោលដៅឆ្ពោះទៅរកភាពជាដៃគូ ស្រាវជ្រាវ យើងក៏ត្រូវការមើលឯកន្លែងផ្សេងៗក្នុងរង្វង់នៃការស្រាវជ្រាវ ដែលយើងបានជួបប្រទះនឹងការបារម្ភផ្សេងៗ ដែលតំរូវអោយ យើងយកចិត្តទុកដាក់ពីបញ្ហាសីលធិម ។

ដើម្បីធានាថាយើងនឹងធ្វើអោយការស្រាវជ្រាវស៊ីគ្នានឹងភាពទទួលខុសត្រូវត្រឹមត្រូវតាមសីលធម៌
យើងត្រូវការសួរខ្លួនឯងនូវសំនួរដែលនឹងជួយយើងអោយបានដឹងច្បាស់លាស់ថា
យើងវាងវៃឆាប់ដឹងពីតំរូវការនៃភាពជាដៃគូនៃសហគមន៏ របស់យើង។
យើងត្រូវការរក្សាកំរិតខ្ពស់នៃការយល់ដឹងដ៏ត្រឹមត្រូវតាមសីលធម៌គ្រប់តំណាក់កាលនៃវង្វង់នៃការស្រាវជ្រាវ គឺមិនត្រឹមតែពេលចាប់ផ្តើមគំរោងការប៉ុណ្ណោះទេ ថែមទាំងដំណើរការដែលបន្តតាមរយៈការអនុវត្តន៏គំរោងការនេះផង។
វិធីមួយក្នុងការធ្វើយ៉ាងដូច្នេះ គឺគ្រោងតំណាក់កាលផ្សេងៗនៃវង្វង់ការស្រាវជ្រាវ និងចូលរួមគិតរកសំនួរអ្វីដែលយើងគួរតែសួរដើម្បីបង្កើនសមត្ថភាពរបស់យើងក្នុងការ ធ្វើការជាមួយគំរូភាពជាដៃគូដែលមានមូលដ្ឋានក្នុងសហគមន៏។
ឧទាហរណ៍ដូចជា យើងប្រហែលជាចង់សួរ:

<u>ក្នុងតំណាក់ការគ្រោងគំរោងការ:</u>

- តើខ្ញុំកំពុងប្រឡូកនឹងសហគមន៏បានដល់កំរិតណាហើយ?
- តើសហគមន៏មានដំណើរការដល់ណាហើយ?
- តើមានប្រយោជន៏អ្វីខ្លះសំរាប់សហគមន៏?
- តើវប្បធម៌និងប្រពៃណីនៃសហគមន៏ត្រូវបានគេគោរពយ៉ាងដូចម្តេច?

<u>ក្នុងតំណាក់ការប្រមូលពិតមាននៃគំរោងការ:</u>

- តើអ្នកចូលរួមត្រូវបានគេជ្រើសរើសយ៉ាងដូចម្តេច?
- តើសំនួរសំរាប់ការស្រាវជ្រាវត្រូវបានគេជ្រើសរើសយ៉ាងដូចម្តេច (និងដោយសារអ្នកណា)?
- តើរឿងផ្ទាល់ខ្លួននិងការសំងាត់របស់មនុស្សម្នាក់ៗ និងសហគមន៏ដែលទាក់ទិន ត្រូវបានការពារយ៉ាងដូចម្តេចខ្លះ?
- តើត្រូវប្រើវិធីបែបណាខ្លះ (ហើយរបៀបទាំងនោះត្រូវបានគេជ្រើសរើសយ៉ាងដូចម្តេច)?
- តើពិតមានដែលបានប្រមូលត្រូវប្រើប្រាស់យ៉ាងដូចម្តេចខ្លះ?

<u>ក្នុងតំណាក់កាលវិភាគទិន្នន័យ:</u>

- តើពិតមានដែលប្រមូលបាននឹងត្រូវវិភាគ ឬបកប្រែយ៉ាងដូចម្តេចខ្លះ?
- តើសហគមន៏មានអ្វីសំរាប់បញ្ចូលក្នុងដំណើរការវិភាគឬទេ?

<u>នៅចុងបញ្ចប់នៃគំរោងការ:</u>

- តើនឹងមានការផ្លាស់ប្តូរណាមួយដែលអាចកើតឡើង ត្រូវបានចាប់ផ្តើមដោយសារលទ្ធផលផ្សេងៗស្រាវជ្រាវ?
- តើតួនាទីនៃអ្នកស្រាវជ្រាវនិងសហគមន៏ក្នុងការកំនត់ថាការផ្លាស់ប្តូរនេះដូចអ្វីនោះមានអ្វីខ្លះ?

សួរសំនួរទាំងនេះមិនមែនធានាថាការស្រាវជ្រាវរបស់យើងគឺត្រឹមត្រូវតាមសីលធម៌ និងត្រូវបានបញ្ចូលគ្នាជាមួយនឹងគំរូស្រាវជ្រាវ ដែលមានមូលដ្ឋានក្នុងសហគមន៏នោះទេ តែការសួរសំនួរទាំងនេះគឺពិតជាជួយយើងអោយនៅតែវាងវៃឆាប់យល់ដឹងថា អ្វីៗដែលយើងធ្វើ ក្នុងកំឡុងពេលស្រាវជ្រាវប៉ះពាល់ដល់ភាពជាដៃគូដែលមានមូលដ្ឋានក្នុងសហគមន៏។ ដំណើរការនេះជួយយើងក្នុងការបង្កើតបទពិសោធន៏ ស្រាវជ្រាវដែលឆ្លុះបញ្ចាំងយ៉ាងពេញលេញពីបំនងរបស់យើងដែលចង់គោរពសិទ្ធិ ភាពផ្ទាល់ខ្លួន និងភាពថ្លៃថ្នូរនៃអ្នកចូលរួមស្រាវជ្រាវដែលជិតគ្នានឹងគោលដៅនៃគំរោងការដែលរស់រវើក និងប្រកបដោយវិទ្យាសាស្ត្ររបស់អ្នកស្រាវជ្រាវ។

# សំនួរពីភាពជាដៃគូការស្រាវជ្រាវដំបូងក្នុងសហគមន៍

នៀម ក្រេត (**Niem Kret**)

## សំណួរសំរាប់សហគមន៍

1. ក្នុងនាមជាសមាជិកសហគមន៍ម្នាក់ តើអ្នកធ្លាប់បានគេប្រាប់ទេថាការសិក្សាស្រាវជ្រាវដែលបានគ្រោងទុកមួយគឺដើម្បីធ្វើអ្វីឬទេ?
2. ក្នុងនាមជាសមាជិកសហគមន៍ម្នាក់ តើអ្នកធ្លាប់បានគេអញ្ជើញអោយជួយក្នុងការរៀបចំកម្មវិធីស្រាវជ្រាវហើយតើកម្មវិធី ស្រាវជ្រាវនោះទំនងជាមានផលប្រយោជន៍ដល់សហគមន៍ឬទេ?
3. តើធ្លាប់ពិចារណាថា តើការស្រាវជ្រាវគួរតែរៀបចំរបៀបម៉េចដើម្បីអោយលទ្ធផលទំនងជាអាចអនុវត្តន៍ផ្ទាល់ក្នុងការជំរុញ បញ្ហាការបារម្ភផ្សេង១ដល់សហគមន៍?
4. ក្នុងនាមជាសមាជិកសហគមន៍ម្នាក់ តើអ្នកធ្លាប់ត្រូវបានគេអញ្ជើញទៅចូលរួមដោយមានសិទ្ធិស្មើគ្នា ក្នុងជំហានទាំងអស់ក្នុងរង្វង់នៃការស្រាវជ្រាវដូចជា ការស្រាវជ្រាវរហូតដល់មានបទពិសោធន៏នៃ ការរកពតិមានដើម្បីដោះស្រាយបញ្ហាបច្ចុប្បន្ន?

សមាជិកសហគមន៍ជាញឹកញាប់សរសើរអំពីៈ សាលារៀន សាកលវិទ្យាល័យ ស្ថាប័ន និងអង្គការផ្សេង១ ហើយជឿជាក់ថា អ្នកស្រាវជ្រាវចៀសមិនរួចពីធ្វើការដើម្បីអោយជីវិតមនុស្ស និងសហគមន៍កាន់តែប្រសើរ ។ ដោយគ្មានបទពិសោធន៍ មិនល្អខះ ជាមួយអ្នកស្រាវជ្រាវ ឬបទពិសោធន៍មិនល្អពីការចូលរួមស្រាវជ្រាវ សមាជិកសហគមន៍បន្តចង់ជួយក្នុងការសិក្សាស្រាវជ្រាវយ៉ាងសកម្ម ។

ការប្រឡូកនឹងសហគមន៍ក្នុងការរៀបចំបង្កើតការស្រាវជ្រាវអាចមានប្រយោជន៍យ៉ាងច្រើនរួមមានៈ

- សមាជិកសហគមន៍មានចំណេះដឹង និងពតមានដ៏មានតំលៃដែលអាចជួយការសិក្សាស្រាវជ្រាវ ។ ឧទាហរណ៏ដូចជា ចំណេះដឹងពីរចនាសម្ព័ន និងសមាសភាពនៃសហគមន៍ គោលនយោបាយក្នុងស្រុក បញ្ហាក្នុងស្រុកជាអចិន្ត្រៃយ៍ ឬការប្រែប្រួលជាលំដាប់ និងការផ្លាស់ប្តូរនៃសហគមន៍ប៉ុន្មានឆ្នាំកន្លងមកនេះ ។

## សំណួរសំរាប់អ្នកស្រាវជ្រាវ

1. សំណួរអ្វីដែលអ្នកគួរតែសួរខ្លួនឯងមុនចាប់ផ្តើមការសិក្សា ស្រាវជ្រាវ ជាមួយក្រុមដែលដំបូង?
2. តើអ្នកចូលរកធនធាន និងពិតមានរបស់សហគមន៍យ៉ាងដូចម្តេច? តើអ្នកមានគំរោងចូលរកដោយមិនចូលប្រឡូកជាមួយនឹងសមាជិក សហគមន៍ ឬក៏អ្នកដឹកនាំឬ?
3. ពេលដែលអ្នកធ្វើការសិក្សាស្រាវជ្រាវ តើផលប្រយោជន៏អ្វី នឹងបានមកពីការធ្វើការជាមួយសមាជិកសហគមន៏? តើមានអ្វីខ្លះដែលជា ឧបសគ្គរាំងស្ទះ?
4. តើបញ្ហាដែលត្រឹមត្រូវតាមសីលធិមអ្វីខ្លះដែលអ្នកគួរតែយកមក ពិចារណាមុនពេលធ្វើការសិក្សាស្រាវជ្រាវ?
5. តើអ្នកចង់ទទួលបានបញ្ជីសំនួរនិងការអនុវត្តន៏ដែលបានរៀបចំ និងមានតុល្យភាពយ៉ាងល្អឬទេ?

ទាំងនេះគ្រាន់តែជាសំនួរខ្លះដែលអ្នកអាចជាចង់ពិចារណានៅពេលដែល អ្នករៀបចំធ្វើការស្រាវជ្រាវ ។ ការស្រាវជ្រាវផ្សេង១ តំរូវ បច្ចេកទេស ខុស១គ្នា ប៉ុន្តែមានការស្រាវជ្រាវជាច្រើនដែលទាក់ទិន នឹងសមាជិក សហគមន៍ និងសហគមន៏ ។ ភាពជាដៃគូប្រហែលជាពិបាកក្នុងការសំរេច ជោគជ័យ ប៉ុន្តែក្នុងពេលជាមួយគ្នានេះ ការស្រាវជ្រាវនៃ ភាពជាដៃគូ អាចផ្តល់ការពេញចិត្តនិងមានសក្តានុពលក្នុងការនាំយកនូវ ប្រយោជន៏ ដ៏អស្ចារ្យដល់អ្នកស្រាវជ្រាវនិងសហគមន៏ ។ ផលប្រយោជន៏ទាំងនេះ រួមមានៈ

- ទិន្នន័យនិងបទពិសោធន៏ស្រាវជ្រាវដែលបញ្ជាក់បញ្ហានៃភាព បារម្ភដ៏ធំបំផុតដល់អ្នកទទួលផល
- ការដែលអាចកើតឡើងបានកើនឡើងលទ្ធផលនៃការស្រាវជ្រាវ ដែលបានសាយភាយ និងធ្វើអោយអ្នកស្តាប់តាមដាន អន្ទះសារចង់ អនុវត្តន៏តាមបទពិសោធន៏នេះ ។
- ការសិក្សាស្រាវជ្រាវដែលមានប្រសិទ្ធិភាព និងការបន្តនៃការស្រាវជ្រាវគឺថាការស្រាវជ្រាវនេះទំនងជារៀបចំបាន ប្រសើរនៅពេល ដែលវាទាក់ទិននឹង

- ការយល់ដឹងយ៉ាងស៊ីជំរៅនៃភាពខុសគ្នាក្នុងវប្បធម៌មួយ
- ការយល់ដឹងក្នុងការពង្រឹងភាពមានប្រយោជន៍និងលទ្ធភាពនៃការស្រាវជ្រាវដែលបានធ្វើមកហើយក្នុងសហគមន៍
- ចំណេះដឹងទៅលើអ្វីដែលជាតំរូវការ និងចំនាប់អារម្មណ៏នៃសហគមន៍
- សមត្ថភាពដើម្បីជួយអ្នកស្រាវជ្រាវចូលឆ្ពោះទៅសហគមន៍ និងធនធានរបស់សហគមន៍
- សមត្ថភាពក្នុងការបង្កើនការប្រើធនធាន ការបំរើ និងពតិមាន របស់សហគមន៍
- ការមើលឃើញនៃតំរូវការយ៉ាងច្រើនដែលបានថ្លឹងថ្លែងយ៉ាងល្អ អាចបន្ថែមការស៊ីជំរៅទៅការសិក្សាស្រាវជ្រាវ
- សមាជិកសហគមន៍អាចបន្តការអនុវត្តន៍ និងប្រើការសិក្សាស្រាវជ្រាវ ប្រសិនបើពួកគេប្រឡូកក្នុងការសិក្សាស្រាវជ្រាវ។ ឧទាហរណ៏គឺអ្នកស្រាវជ្រាវនៃសហគមន៍ដែលកំពុងញុំាត្រីទឹកសាបដែលមានជាតិបារ៉តពុល ប្រហែលជាស្ម័គ្រឈប់ញុំា ដើម្បីការពារសុខភាពរបស់ពួកគេ។
- សមាជិកសហគមន៍អាចជួយ ការស្រាវជ្រាវដើម្បីរៀបចំគំរោង ឧបករណ៏ ការវាយតំលៃ និងការអនុវត្តន៍ស្រាវជ្រាវ កាន់តែល្អប្រសើរ។
- ភាពជាដៃគូអាចបង្កើនសមត្ថភាពនៃសហគមន៍ ដោយទទួលការហ្វឹកហ្វឺនពីអ្នកស្រាវជ្រាវ។
- សមាជិកសហគមន៍ដែលបានប្រឡូកក្នុងការគ្រោង និងការអភិវឌ្ឍន៏ការសិក្សាស្រាវជ្រាវ នឹងយល់ពីការស្រាវជ្រាវកាន់តែប្រសើរថែមទៀត។
- អ្វីដែលប៉ះពាល់សមាជិកសហគមន៍ពីការស្រាវជ្រាវ
- បង្កើតសមត្ថភាពសហគមន៍
- ការអភិវឌ្ឍន៏សហគមន៍
- ការបង្កើនកំលាំងសហគមន៍
- ការរកឃើញរបស់សហគមន៍ពីប្រភពដើម មូលហេតុនៃបញ្ហា តំរូវការនៃសហគមន៍
- បង្កើនទំនាក់ទំនងសហគមន៍ ទំនាក់ទំនងនឹងសង្គមដើម អ្នកដែលជាបង្គោល ដូចជាអ្នកស្រាវជ្រាវ អ្នកវិទ្យាសាស្ត្រ សមាជិកសហគមន៍ អង្គការដែលមានមូលដ្ឋានក្នុងសហគមន៍ ស្ថាប័ន សាកលវិទ្យាល័យ អ្នកដឹកនាំសហគមន៍ អ្នកផ្តល់ពតិមាន សំខាន់ៗ និង អ្នកចូលរួមនានា។

- ការស្រាវជ្រាវដែលមានប្រសិទ្ធិភាពនាំទៅដល់ ផលប្រយោជន៍សហគមន៍ផ្ទាល់និងមានឳកាសល្អថែមទៀត ក្នុងការអនុវត្តន៏ការស្រាវជ្រាវ និងផលប្រយោជន៍សហគមន៍។ ការអនុវត្ត និងការរៀបចំ ស្រាវជ្រាវ នឹងត្រូវពិចារណា មែកធាងទាំងអស់ ការយល់ឃើញរបស់ អ្នកស្រាវជ្រាវ ការយល់ឃើញ របស់សហគមន៍ និងការគាំទ្រ និងការប្រឆាំង នៃការសិក្សា ស្រាវជ្រាវទាំងអស់។
  - តើវប្បធម៌នៃសហគមន៍ជាអ្វី? តើជាប្រពៃណីផ្សេងៗឬ?
  - តើការស្រាវជ្រាវនឹងប៉ះពាល់សហគមន៍អ្វីខ្លះ?
  - តើផលប្រយោជន៍នេះគឺសំរាប់សហគមន៍ទេ? ឬក៏ សំរាប់ខ្លួន ខ្ញុំ ឬសំរាប់អ្នកស្រាវជ្រាវតែប៉ុណ្ណោះ?
  - តើខ្ញុំគួរតែទុកការផ្លាស់ប្តូរជាវិជ្ជមាន ឬក៏អវិជ្ជមាន ក្នុងសហគមន៍? តើនឹងមានភាពលំអៀង ភាពអាម៉ាស ឬក៏ការ ប្រកាន់ពូជសាសន៍ ដោយសារការស្រាវជ្រាវឬ?
- អ្នកស្រាវជ្រាវអាចមានការយល់ឃើញ និងចំណេះដឹងនៃ សហគមន៍ច្រើនទៀតពេលដែលមានភាពជាដៃគូមួយ។ ឧទាហរណ៏: ភាពខុសគ្នានៃសហគមន៍ វប្បធម៌ ការប្រែប្រួលជាលំដាប់ ឬការផ្លាស់ប្តូរ ប៉ុន្មានឆ្នាំនេះ ដូចជាមនុស្សជាច្រើនមាន ជំងឺទឹកនោមផ្អែម និងភាពធាត់ពេក។ ការសំលឹងទៅមើលសេចក្តីត្រូវការផ្សេងៗ របស់សហគមន៍។ សហគមន៍ផ្តល់នូវ គោលការណ៏ ការយល់ដឹង និងចំណេះដឹង ឬក៏ សហគមន៍ ជាច្រើនទៀត
- ភាពខុសគ្នានៃសហគមន៍រួមបញ្ចូលទាំងក្រុមនៃជនជាតិផ្សេងៗ វប្បធម៌ និងការអនុវត្តន៏ តើសហគមន៍ត្រូវធ្វើអ្វីដំបូងគេបង្អស់ រួមនឹងការ សំរបសំរួល ដើម្បី ឆ្ពោះទៅការប្រថុយប្រថាន ឬឥទ្ធិពលលើការផ្លាស់ប្តូរនៃ សង្គម និងការប្រែប្រួលនៃបរិដ្ឋាន
- អ្នកស្រាវជ្រាវអាចមានការយល់ឃើញកាន់តែល្អថែមទៀតទៅលើបញ្ហា ដែលបានរកឃើញ ឬបញ្ហានៃការស្រាវជ្រាវ។ ចូរសម្លឹងមើលបញ្ហាអោយបានច្បាស់ជាងនេះទៅទៀត ការសន្និដ្ឋានបញ្ហាផ្សេងៗ និងការយល់ ដឹង ឬសីលធម៌ និងការសិក្សាស្រាវជ្រាវដែល មានប្រយោជន៍។
- អ្នកស្រាវជ្រាវអាចយល់ពីតម្លៃសហគមន៍ ដូចជា ការហ្វឹកហ្វឺន ការងារ

បន្ថយការប្រកាន់ពូជសាសន៍ និងយល់ច្រលំ រវាងសហគមន៍ និង អ្នកស្រាវជ្រាវ

- ភ្ជាប់ការស្រាវជ្រាវទៅនឹងការស្រាវជ្រាវស្រដៀងគ្នានៅក្នុងសហគមន៍ផ្សេងៗទៀតហើយការត្រូវការអោយដឹង និងការអនុញ្ញាត នៃសមាជិកសហគមន៍
- សមាជិកសហគមន៍ប្រហែលជាចង់ចូលរួមក្នុងវិធីការពារនានា
- សមាជិកសហគមន៍នឹងយល់ការយល់នូវឃើញរបស់អ្នកស្រាវជ្រាវនិងអ្នកស្រាវជ្រាវអាចយល់ពីសហគមន៍ និងព្រឹត្តិការណ៍នៃវប្បធម៌
- យល់ពីសិទ្ធិនៃសមាជិកសហគមន៍
- តើផលវិបាកនៃការស្រាវជ្រាវពីសហគមន៍ និងសមាជិកសហគមន៍មានអ្វីខ្លះ?
- តើកម្មសិទ្ធិនៃសហគមន៍ដែលអ្នកស្រាវជ្រាវប្រហែលជាត្រូវការយល់ និងធ្វើការជាមួយនោះជាអ្វីខ្លះ?
  - សហគមន៍អាចមានគំនិតផ្សេងៗ និងដំណោះស្រាយឆ្ពោះទៅការសិក្សាស្រាវជ្រាវ។
- តើទ្រព្យ និងការទទួលខុសត្រូវនៃសហគមន៍ជាអ្វី?
  - ចំណេះដឹងនៃសហគមន៍ពីគំនិតថ្មីៗសំរាប់ការផ្លាស់ប្តូរយល់ពីជំរៅនៃបញ្ហាសហគមន៍ និងរបៀបដែលអ្នកស្រាវជ្រាវវិភាគបញ្ហានេះជាភារៈនាទី ប៉ុន្តែសមាជិកហៅវាថាជាទ្រព្យ
- តើអ្វីខ្លះជាការកេរិតនៃការស្រាវជ្រាវក្តីសង្ឃឹមសហគមន៍?
  - សមាជិកសហគមន៍អាចមានការយល់ដឹងដ៏មានតំលៃទៅលើការសិក្សាស្រាវជ្រាវពីបទពិសោធន៍មុនរបស់គេ ជាមួយអ្នកស្រាវជ្រាវ ឬក៏គ្រាន់តែនៅក្នុងសហគមន៍ប៉ុណ្ណោះ
- សមាជិកសហគមន៍ប្រហែលជាចង់ចូលរួមថែមទៀត ប្រសិនបើពួកគេឃើញដំណោះស្រាយដ៏មានប្រសិទ្ធិភាពទៅលើបញ្ហា ទាំងអស់បាន

គឺជាការសំខាន់ណាស់ សំរាប់សមាជិកសហគមន៍ ឬក៏វាជាការដ៏ល្អ បំផុត សំរាប់អ្នកស្រាវជ្រាវក្នុងការធ្វើ បញ្ជីសំនួររបស់ពួកគេនៅពេលរសៀល ពីព្រោះសមាជិក សហគមន៍ភាគច្រើនធ្វើការនៅវេនទីពីរ ឬវេនទីមួយ។

- អ្នកស្រាវជ្រាវអាចចូលប្រើពត៌មាន និងធនធានដែលអាចប្រើ បានពីសមាជិកសហគមន៍។ ឧទាហរណ៍: សមាជិកសហគមន៍ចេះដឹងពីការបំរើ សង្គមដែលពួកគេប្រើ ហើយហេតុអ្វីពួកគេប្រើការបំរើនេះ ឬក៏ហេតុអ្វីពួក គេមិនប្រើសេវាកម្មនេះ។ សមាជិកសហគមន៍អាចដឹង ពីបញ្ហាក្នុង សហគមន៍ ដែលពួកគេបានរស់នៅក្នុងជីវិតរបស់ពួកគេទៅហើយ ដូចជា ពេលជាតិប្រេងត្រូវគេចោលលើដី ឬក៏របៀបដែល អ្នកជិតខាងមានជំងឺ ឆ្លងដោយសារសត្វកណ្តុរ ឬជំងឺដែលមិនស្គាល់មុខខ្លះៗ ឬបញ្ហាសុខភាព ប្រហែលជា ៥០ ឬ៦០ឆ្នាំមុន។ របៀបដែលពួកគេញ៉ាំត្រីដែលមានជាតិ បារ៉ត ឬជាតិគីមីពុលកាលពី ១០ឆ្នាំមុន។
- អ្នកស្រាវជ្រាវប្រហែលជាពីតួនាទីខ្លួនគេ ភាពទទួលខុសត្រូវ និងកាតព្វកិច្ច របស់ពួកគេចំពោះសមាជិកសហគមន៍ និងសហគមន៍ទាំងមូល។ គោរពសហគមន៍ គោរពអ្នកដែលរស់នៅក្នុងសហគមន៍ និងជីវិតពួកគេបាន ត្រូវគេកំពុងរុករាន និងសួរសំណួរជាច្រើន ដោយសារតែ អ្នកដែលជាអ្នក ស្រាវជ្រាវនុំះអី។
- ការតបត និងការបញ្ចូលរបស់សហគមន៍ទៅលើ
  - គំរោងការស្រាវជ្រាវ
  - បែបយ៉ាងនិងបញ្ហានៃការស្រាវជ្រាវ
  - ការអនុវត្តន៍ការស្រាវជ្រាវ
  - ការវាយតំលៃលើការស្រាវជ្រាវ
  - បទពិសោធន៍និងលទ្ធផលនៃការស្រាវជ្រាវ
- អ្នកស្រាវជ្រាវអាចផ្តល់ទៅអោយសហគមន៍ដោយការហ្វឹកហ្វឺនសមាជិកសហគមន៍ បង្កើនសហការ ការរួបរួមគ្នាជាមួយសហគមន៍នានា។
- អ្នកស្រាវជ្រាវគួរតែផ្តល់ការទទួលស្គាល់របស់សហគមន៍ ដាក់បញ្ចូលទៅក្នុងការសិក្សាស្រាវជ្រាវ
- ការប្រើការស្រាវជ្រាវប្រហែលជាធម្មតា ដូចជាការប្រើ ពាក្យសព្ទ និងពាក្យបច្ចេកទេស ដែលសមាជិកសហគមន៍អាចយល់ដឹង។
- ការផ្តោតអារម្មណ៍លើការការពារ

# មូលដ្ឋាននៃការស្រាវជ្រាវរកភាពជាដៃគូ

## របៀបដែលសហគមន៍ថ្លឹងថ្លែងកម្លាំងក្នុងការស្រាវជ្រាវភាពជាដៃគូ

ម៉ាថីន ស៊ីរ៉ែត **(G. Martin Sirait)**

នៅពេលដែលយើងនិយាយពីកម្លាំងគឺយើង កំពុងលើក ឡើងបញ្ហាពីអ្នកណាគ្រប់គ្រងអ្នកណា ហើយអ្នកណាគ្រប់គ្រងលើអ្វី បញ្ហាកម្លាំងក្នុងដំណើរការស្រាវជ្រាវនេះ គឺ ដោះស្រាយនឹងបញ្ហា ដូចជា "អ្នកណាជាអ្នកសំរេចលើរបៀបវារៈ ការប្រមូលទិន្នន័យហើយនឹងវិធីសាស្ត្រក្នុងការស្រាវជ្រាវ?" "តើអ្នកណាពន្យល់ពីការសំរេច ចិត្តផ្សេងៗ អ្នកណាជាម្ចាស់នៃទិន្នន័យ" ជាដើម។ នៅពេលដែលមានភាពខុសគ្នាដ៏ធំរវាងសហគមន៍ និង"អ្នកស្រាវជ្រាវ" ដែលជាញឹកញាប់បានកើតឡើង ដំបូន្មានខ្លះៗខាងក្រោមផ្តល់វិធីផ្សេងៗដែលសហគមន៍អាចថ្លឹងថ្លែងធ្វើអោយកំលាំងក្នុងការស្រាវជ្រាវនេះ។

### ចូរចូលរួមក្នុងគណៈកម្មាធិការនៃការស្រាវជ្រាវ

សមាជិកសហគមន៍អាចដើរតួនាទីយ៉ាងសកម្មដោយចូលរួមក្នុងគណកម្មាធិការនៃការស្រាវជ្រាវ ក្នុងគណកម្មាធិការ បែបនេះ សមាជិកសហគមន៍អាចជួយកំណត់របៀបវារៈ វិធីស្រាវជ្រាវ សំណួរដែលត្រូវសួរជាដើម។ ឧទាហរណ៍ៈ កម្មវិធី ស្រាវជ្រាវពីមហារីក (Wai'anae) នៅហាវៃបានបង្កើតគណកម្មាធិកាស្រាវជ្រាវសហគមន៍មួយ ដែលមានអ្នកតំណាង សហគមន៍ អ្នកជំនាញខាងផ្នែកសុខភាព និងអ្នកស្រាវជ្រាវខាងវិទ្យាសាស្ត្រ។ ពួកគេធ្វើការរួមគ្នាដើម្បីអភិវឌ្ឍន៍ និងស្វែងរក ថវិការសំរាប់គំរោងការនេះ។ ក្នុងករណីនេះ សហគមន៍មានឱកាស ប្រើការសំរេច ពីដើមដំបូងបំផុត នៃការស្រាវជ្រាវ។

### ចូរចងចាំថាសមាជិកសហគមន៍ក៏ជាអ្នកស្រាវជ្រាវផងដែរ

តើអ្នកណាជា" អ្នកស្រាវជ្រាវ " ក្នុងនៃការស្រាវជ្រាវភាពជាដៃគូ? ក្រុមទាំងអស់ដែលធ្លាប់ប្រឡូកក្នុងការស្រាវជ្រាវ ជាអ្នកស្រាវជ្រាវ សហគមន៍អាចជ្រើសរើសសមាជិកខ្លះពីក្នុងសហគម៍ដើម្បីធ្វើការហ្វឹកហ្វឺន និងក្លាយជា អ្នកជំនាញ ចំពោះរឿងរ៉ាវរបស់សហគមន៍។ អ្វីដែលអាចកើតឡើយគឺការបង្កើតធនធានមនុស្សតាមរយះវីធីស្រាវជ្រាវ គោលដៅមួយ នេះអាចបង្កើត សមត្ថភាពខាងក្នុងនៃសហគមន៍។ បន្ទាប់មកទៀត អ្វីដែលកើតឡើងគឺការដឹកនាំថ្មី ក្នុង សហគមន៍។ ឧទាហរណ៍ : ភាពជាដៃគូនៃការផ្សងព្រេងថ្មីក្នុងទីក្រុងឡូវែល ជនក្មេងៗត្រូវបានគេហ្វឹកហ្វឺនអោយក្លាយជា "អ្នកទូតទន្លេ " ដែលបន្ទាប់មកបាន បង្រៀនសមាជិកសហគមន៍ពីបញ្ហាបរិដ្ឋាន ដោយប្រើរឿងល្ខោននិងល្បែងកំសាន្តផ្សេងៗ។

### ចូរធ្វើអោយសហគមន៍អោយកាន់តែមានកំលាំងនិងមានតំលៃថែមទៀត

សហគមន៍នីមួយៗមានគោលការណ៍សំខាន់និងប្លែកៗជាច្រើន កម្មវិធីនៃការស្រាវជ្រាវមួយនឹងប្រព្រឹត្តទៅមុខជានិច្ចដោយមាន គោលការនេះដែលនៅពេលជាមួយគ្នានេះ ប្រើជាកំលាំងរុញច្រានខាងក្នុងសំរាប់បំលាស់ប្តូរសង្គម បន្ទាប់មកការស្រាវជ្រាវអាចពង្រឹង សហគមន៍អោយមានភាពដូចគ្នាប្រកបដោយភាពថ្លៃថ្នូរ។ ឧទាហរណ៍ដូចជា ការស្រាវជ្រាវដែលបានធ្វើឡើងនៅហាវ៉ៃ ពួកគេបានប្រើ គោលការណ៍ជំនាន់ដើមរបស់ជនជាតិហាវ៉ៃ ដូចជាកូកួ (Kokua) (បំណងជួយគេដោយមិនសង្ឃឹមយកការតបស្នង) អាឡូហា

(Aloha) (សេចក្តីស្រឡាញ់) ហើយឡូកាហ៊ី (Lokahi) (ភាពចុះសំរុងគ្នា) ថែមទាំង គំរូនៃការប្រាស្រ័យទាក់ទងគ្នា ដូចជាមូលដ្ឋាននៃកម្មវិធីសិក្សាដើម្បីលើកតំកើងការត្រួតពិនិត្យជំងឺមហារីកដោះនិងស្បូន។

## ទិន្នន័យដែលជាកម្មសិទ្ធិរួម

ទិន្នន័យជាញឹកញាប់ត្រូវបានប្រមូលក្នុងសហគមន៍មួយ ហើយសមាជិកសហគមន៍មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ ប្រមូល ហើយនិងវិភាគទិន្នន័យនេះ ដូច្នេះវាជាការត្រឹមត្រូវមួយ ប្រសិនបើសហគមន៍អាចឃុំគ្រងលើទិន្នន័យបានការឃុំគ្រង លើបទពិសោធន៍ផ្សេងៗរាប់បញ្ចូលទាំងការដាក់ចូលឈ្មោះនៃសហគមន៍ក្នុងការបោះពុម្ពផ្សាយនូវការរកឃើញទាំងឡាយនេះ។ ទិន្នន័យរួមក៏មានន័យថាសហគមន៍អាចបកស្រាយប្រាប់ពីបទពិសោធន៍ទាំងនេះ ភាពមើលទៅមុខបានវែងឆ្ងាយរបស់សហគមន៍អាចថាមានតំលៃណាស់ដែរ។ នៅចំណុចនេះ សហគមន៍អាចសំរេចថាតើបទពិសោធន៍ណាមួយដែលអាចមានប្រយោជន៍ សំរាប់ពួកគេ និងមួយណាគ្មានប្រយោជន៍។

## បង្កើតក្រុមស្រាវជ្រាវនៃស្ថាប័នរបស់សហគមន៍ ឬក៏ក្រុមស្រាវជ្រាវនៃសហគមន៍

ការពិភាក្សាលើ IRB (ក្រុមស្រាវជ្រាវនៃស្ថាប័ន) ដែលមានស្រាប់ភាគច្រើនគឺ អំពីការការពារនៃសិទ្ធិមនុស្ស (ម្នាក់ៗ)ជាជាងការការពារសិទ្ធិរបស់សហគមន៍ លើសពីនេះទៅទៀត សមាជិកនៃ IRB មិនរាប់បញ្ចូលអ្នកតំណាងសហគមន៍ ជាច្រើននាក់ទេ។ ដូច្នេះយើងត្រូវការ IRB ផ្សេងមួយទៀត (ឬ IRB ដែលបានកែប្រែហើយ) ដែលអាចតំរូវតាមចំណូលចិត្តរបស់សហគមន៍ និងការពារសិទ្ធិរបស់សហគមន៍ ( IRB របស់សហគមន៍ ឬក៏ក្រុមស្រាវជ្រាវរបស់សហគមន៍) សូមមើល "អ្វីៗដែលអ្នកតែងតែចង់ដឹងពី IRB" ផងដែរ។ ឧទាហរណ៍ក្នុងការស្រាវជ្រាវពីសេនេទិច (ការបន្តពូជ) ក្នុងចំនួន ពលរដ្ឋជាច្រើនដែលត្រូវគេទទួលស្គាល់ក្នុងសង្គម (កុលសម្ព័ន្ធ Apach, នៅរដ្ឋ Oklahoma) ក្រុមស្រាវជ្រាវសហគមន៍នៃ កុលសម្ព័ន្ធ CRB មានតួនាទីយ៉ាងសំខាន់ក្នុងការព្យាបាលពិនិត្យពិច័យសារឡើងវិញនូវឈាមគំរូ ឆ្ពោះទៅការពិភាក្សាលើការ សំរេចចិត្តជាច្រើននិងការផ្ទុកទិន្នន័យ។

ជំហានដំបូងនៃការស្រាវជ្រាវភាពជាដៃគូមានមូលដ្ឋាន គឺចង់ផ្តល់អំណាចអោយសហគមន៍ និងក្រុមដទៃទៀត ដើម្បីបង្កើនអំណាចលើជីវិតការរស់នៅរបស់ពួកគេ។

# អ្វី%ដែល អ្នកតែងតែចង់ដឹងពី IRB

**សុខមករា ជីវ (Sokmeakara Chiev)**

អ្នកប្រហែលជានិយាយថា "តើ IRB ជាអ្វី?" ហើយអ្នកតែងតែឆ្ងល់និងចង់ដឹងពីវាអោយបានច្បាស់ ប្រសិនបើអ្នកចាប់អារម្មណ៍ក្នុងការបង្កើតភាពជាដៃគូស្រាវជ្រាវ ឬក៏អ្នកបានចាប់ផ្តើមរួចហើយ អញ្ចឹងចំលើយនៃសំនួរហ្នឹងគឺមិនតិចទេ ដូច្នេះយើងនឹងចាប់ផ្តើមពីដំបូងបំផុត។

IRB គឺជាក្រុមត្រួតពិនិត្យនៃស្ថាប័ន។ ក្នុងឆ្នាំ ១៩៧៤ មានសកម្មភាពជាតិមួយបានរកឃើញថាការស្រាវជ្រាវទាំងអស់ដែលឧបត្ថម្ភដោយក្រសួងបំរើការខាងសុខភាពនិងមនុស្ស ត្រូវបានត្រួតពិនិត្យឡើងវិញដោយក្រុមមួយដើម្បីបញ្ជាក់ថា ការស្រាវជ្រាវនោះត្រឹមត្រូវតាមរបៀបមានសីលធម៌។ ឥឡូវនេះ យើងអាចរក IRB ឃើញគ្រប់កន្លែងណាដែលមានអ្នកចូលរួមក្នុងការស្រាវជ្រាវ (ឧទាហរណ៍ដូចជា មន្ទីរពេទ្យ និងសាកលវិទ្យាល័យ) ដើម្បីធានាថាអ្នកចូលរួមនឹងគ្មានគ្រោះថ្នាក់បង់ខាតអ្វីដែលមិនសមហេតុផល។

IRB ពិនិត្យគំរោងស្រាវជ្រាវទាំងអស់ ដើម្បីអោយពួកគេទទួលបានការស្រាវជ្រាវដ៏ត្រឹមត្រូវមួយ ហើយស្ទង់មើលពីគ្រោះថ្នាក់និងផលប្រយោជន៍នៃការចូលរួមនេះ។

តួនាទីរបស់ IRB គឺធានាទាំងច្បាស់ថាអ្នកចូលរួមគ្មានទទួលគ្រោះថ្នាក់ក្នុងកំឡុងពេលចូលរួមការពិសោធន៍នេះ។ IRB ជាធម្មតាមិនជាប់ទាក់ទងទៅនឹងបញ្ហាផ្សេងៗទៀតដូចជា

- តើអ្នកណាកំនត់សំនួរសំរាប់ការស្រាវជ្រាវ? តើសមាជិកសហគមន៍ជាដៃគូដែលមានលទ្ធភាពស្មើគ្នាឬទេ?
- តើបទពិសោធន៍នៃការស្រាវជ្រាវនេះត្រូវបានគេនាំទៅដល់សហគមន៍ដោយវិធីណា? តើនៅក្នុងផ្លូវមួយដែល ផ្តល់ប្រយោជន៍ដល់ពួកគេឬ?
- តើការស្រាវជ្រាវនេះផ្តល់ប្រយោជន៍ដល់សហគមន៍យ៉ាងដូចម្តេចខ្លះ?

នៅពេលដែលភាពជាដៃគូរក្នុងការស្រាវជ្រាវកាន់តែធម្មតាទៅៗ សហគមន៍ជាច្រើនបានចាប់ផ្តើមគិតពីបញ្ហាទាំងនេះហើយនិងគិតពីអ្នកណាដែលកំពុងសំលឹងរកទៅការចាប់អារម្មណ៍ខ្លាំងរបស់ពួកគេ។ ការបារម្ភនេះចងភ្ជាប់ជាមួយការស្គាល់នូវផលប្រយោជន៍នៃការស្រាវជ្រាវ ដែលបានត្រូវប្រគល់ អោយបានធ្វើអោយសហគមន៍ជាច្រើនបង្កើត IRBs នៃសហគមន៍ផ្ទាល់របស់ពួកគេ។ ក្រុមប្រឹក្សានិងសមាជិកអចិន្ត្រៃនៃ សហគមន៍ គឺវាក្លាយជារឿងធម្មតាដែលនៅក្នុងចំណោមសហគមន៍អាមេរិចកាំងដើម (Native American) ទោះបីជាសហគមន៍ ផ្សេងៗទៀតបានអ្វីជាងនេះក៏ដោយ។ IRB នៃសហគមន៍បានបង្កើតសេចក្តីណែនាំផ្ទាល់ខ្លួនរបស់ពួកគេសំរាប់បែបបទនៃការស្រាវ ជ្រាវត្រូវតែអនុវត្តន៏តាម ដោយបង្ហាញបញ្ហាបែបនេះទៅជា:

- ប្រយោជន៍ដល់សហគមន៍
- ភាពឆាប់រំភើបពីវប្បធម៌
- ម្ចាស់កម្មសិទ្ធិទិន្នន័យ

**<u>សំរាប់ពត៌មានបន្ថែមពី IBR នៃសហគមន៏ ចូរពិនិត្យរកមើលនៅ</u>**

- ✓ មជ្ឈមណ្ឌលស្រាវជ្រាវក្រុង Detroit: www.sph.uich..edu/urc
- ✓ ក្រុមដែលផ្តល់ដំបូន្មាននៃសហគមន៏នៅឯ www.supereme.state.az.us/jjsd/cab.htm

# ការពុះពារឧបសគ្គជាច្រើនដើម្បីទៅដល់ភាពជាដៃគូ

**ម៉ារី ម៉ាទីណែលលី (Marie Matinelli)**

ក្នុងនាមជាមេដឹកនាំសហគមន៍ម្នាក់ អ្នកប្រហែលជាចាប់អារម្មណ៍ក្នុងការទាក់ទិននឹងភាពជាដៃគូមួយ ប៉ុន្តែអ្នកមិនប្រាកដថាគួរតែចាប់ផ្តើមពីណាទេ។ អ្នកបានឮយោបល់ល្អខ្លះៗអំពីភាពជាដៃគូ ប៉ុន្តែយោបល់ខ្លះទៀតបាន ចង្អុលបង្ហាញពីបញ្ហាជាច្រើន ដែលកើតមានហើយ អ្នកខ្លះទៀតនិយាយថាភាពជាដៃគូក្នុងការស្រាវជ្រាវកម្របានជោគជ័យណាស់។ ដូច្នេះហើយឧបសគ្គ និងការជំទាស់ផ្សេងៗដែលអ្នកនិងជួបប្រទះនោះ តើអ្នកត្រូវប្រឈមមុខ ដោះស្រាយយ៉ាងដូចម្តេច? ខាងក្រោមនេះជាសំនួរនិងការបារម្ភ ខ្លះៗដែលសហគមន៍ជាច្រើនបានជួបប្រទះនៅពេលដែល ពួកគេចាប់ផ្តើមពិចារណាពីគំនិតដែលទាក់ទិននឹងភាពជាដៃគូស្រាវជ្រាវ។ នៅពេលអ្នកជួបប្រទះឧបសគ្គទាំងឡាយនេះ តើអ្នកធ្វើយ៉ាងណាទើបអាចយកឈ្នះលើឧបសគ្គទាំងនេះបាន?

<u>ការជំទាស់ទី១</u>

តើភាពជាដៃគូនេះផ្តល់ប្រយោជន៍ដល់សហគមន៍ឬទេ?

- វាគឺជាការពិបាកស្មានដឹងដែរថាផលប្រយោជន៍ពីភាពជាដៃគូទាំងអស់បានដល់សហគមន៍ ប៉ុន្តែសហគមន៍ជាច្រើនបានសំរេចជោគជ័យហើយទទួលបានប្រយោជន៍ពីភាពជាដៃគូ ផលប្រយោជន៍ទាំងនេះត្រូវបានគេរកឃើញក្នុងសហគមន៍ផ្សេងៗជាច្រើន ដូចជាសហគមន៍ជនជាតិអាមេរិកាំងឥណ្ឌា (Native American) និងកុលសម្ព័ន្ធដើម (Native Tribes) នៅហាវ៉ៃ។ ដូច្នេះតើគួរចាប់ផ្តើមពីកន្លែងណា? នេះគឺរបៀបខ្លះៗដែលគួរពិចារណា :
- បង្កើតទីប្រឹក្សាមួយក្រុមប្រចាំសហគមន៍
- ចូលរួមក្នុងការរៀបចំគំរោងការណ៍
- បញ្ចេញការបារម្ភនិងជំទាស់របស់សហគមន៍ប្រសិនជាមាន
- ចែកចាយចំណេះដឹងនិងការអន្តរាគមន៍ជាប្រយោជន៍ដល់គ្នាទៅវិញទៅមក

<u>ការជំទាស់ទី២</u>

ក្នុងនាទីជាអ្នកដឹកនាំសហគមន៍ តើយើងត្រូវធ្វើការជាមួយអ្នកស្រាវជ្រាវទាំងអស់នោះយ៉ាងដូចម្តេច នៅពេលដែលពួកគេ គ្រាន់តែចង់ប្រមូលទិន្នន័យរបស់ពួកគេហើយចាកចេញទៅ?

- វាមិនស្រួលទេក្នុងការបង្កើតភាពជាដៃគូ ជាពិសេសពេលដែលក្រុមខ្លះ ដែលចាំតែសម្លឹងឃើញថា ការបង្កើតភាពជាដៃគូមួយមានរបៀបវារៈ គោលដៅនិងគោលបំណងប្រឆាំងផ្សេងៗគ្នាទៅវិញនោះ។ ជាញឹកញាប់ណាស់ ដែលអ្នកស្រាវជ្រាវអាចមើលមិនឃើញពីភាពសំខាន់នៃភាពជាដៃគូពីព្រោះពួកគេជាប់ទាក់ទងនឹងការស្រាវជ្រាវពេក។ ផលវិបាកក្នុងការធ្វើការជាមួយអ្នកស្រាវជ្រាវដែលធ្វើតាមរបៀបជំនាន់មុន គឺថាអ្នកស្រាវជ្រាវអាចផ្តោតអារម្មណ៍ទៅលើ "ផលប្រយោជន៍មនុស្សជាតិ" ការធ្វើអោយមុខងាររគេកាន់តែប្រសើរឡើង ហើយនិងពង្រីកចំណេះដឹងផ្នែកវិទ្យាសាស្ត្រ ។ លទ្ធផលនេះអាចថាជាសហគមន៍ណាមួយតែម្តងដែលផ្តល់

ទិន្នន័យ ដើម្បីឈានទៅដល់គោលដៅខាងលើ នោះអាចបញ្ចប់ដោយមានអារម្មណ៍ថាត្រូវគេជញ្ជក់យកផលប្រយោជន៍ពីខ្លួនដើម្បីអោយឈ្នះលើបញ្ហានេះ សហគមន៍ត្រូវៈ

- បង្កើតការទុកចិត្តគ្នាជាមួយអ្នកស្រាវជ្រាវ
- ចូលរួមក្នុងដំណើរការនៃគំរោងនេះអោយបានច្រើនថែមទៀត
- ជួបជាមួយក្រុមអ្នកស្រាវជ្រាវដើម្បីអោយដឹងថាតើទិន្នន័យនេះត្រូវបានចែកចាយជាមួយសហគមន៍ ឬបើមិន អញ្ចឹងទេត្រូវអោយអ្នកស្រាវជ្រាវបង្រៀនសហគមន៍ពីរបៀបអោយដឹងច្បាស់ថាតើទិន្នន័យមានផលប៉ះពាល់ដល់សហគមន៍ យ៉ាងដូចម្ដេច នោះជំហានទាំងនេះអាចធានាថាទិន្នន័យត្រូវបានប្រើសំរាប់កម្មវិធីអភិវឌ្ឍន៍ដើម្បីបង្កើតគោលនយោបាយ និងបំផ្លាស់ប្ដូរ នៃសង្គម ។

<u>ការជំទាស់ទី៣</u>

អ្នកស្រាវ ជ្រាវ មិនដឹងថាយើងជាអ្នកណា ពួកគេមិនយល់ពីសហគមន៍និងវប្បធម៌របស់យើង តើពួកគេដឹងថាសេចក្ដីត្រូវ ការរបស់សហគមន៍យើងគឺជាអ្វីឬទេ?

- ដើម្បីទទួលបានភាពជាដៃគូដ៏ស្មើគ្នាមួយរវាងអ្នកស្រាវជ្រាវនិងសហគមន៍ យើងគួរតែបង្កើតការអប់រំនិងការហ្វឹកហ្វឺន ។ សហគមន៍ជាច្រើនដែលមិនធ្លាប់បង្កើតភាពជាដៃគូស្រាវជ្រាវ ប្រហែលជាមិនមានការពិសោធន៍គ្រប់គ្រាន់ដែលអាចធានាថា នឹងអាចទទួលផលប្រយោជន៍យ៉ាងពេញលេញពីការចូលរួមនេះនៅឡើយទេ ប៉ុន្តែសហគមន៍ផ្សេងទៀតដូចជាៈ កុលសម្ព័ន្ធ (Native American) មានបទពិសោធន៍លើភាពជាដៃគូផ្សេងៗជាមួយអ្នកស្រាវជ្រាវ ហើយក៏បានបង្កើតនូវគំរូជាច្រើន ដែលអាចដកយកមកប្រើជាគំនិតនិងយោបល់បាន ។ សហគមន៍ទាំងនេះមានមធ្យោបាយធានានូវសមត្ថភាពរបស់សហគមន៍ ដើម្បីជំនះនូវឧបសគ្គនិងការជំទាស់ទាំងអស់ ។ ការចូលរួមគ្នាជាដៃគូគឺមិនងាយស្រួលទេពីព្រោះអ្នកមិនដឹងថា ភាពជាដៃគូទាំងនោះនឹងដឹកនាំដល់កន្លែងណា ឬក៏វានឹងនាំទៅដល់កន្លែងមួយពិតប្រាកដនៅពេលណាទេ ហើយវាកាន់តែពិបាកថែមទៀត បើសហគមន៍នេះជាអ្នកថ្មីថ្មោង ក្នុងការចូលរួមការស្រាវជ្រាវជាដៃគូ ប៉ុន្តែដូចជាសហគមន៍ជាច្រើនទៀត ដែលធ្លាប់ជំនះនូវឧបសគ្គទាំងឡាយនៃភាពជាដៃគូនេះបានសំរេច រីឯសហគមន៍របស់អ្នកក៏គួរតែធ្វើបានដូចគេដែរ ។

# កន្លែងតាំងគ្រឿងវិទ្យាសាស្ត្រនៅក្នុងទីក្រុងឡូវែល

**Kerrie Pharmer**

ក្នុងនាមជាសមាជិកម្នាក់នៃសហគមន៍នេះ នៅពេលខ្លះអ្នកប្រហែលជាផ្តោតអារម្មណ៍ទៅលើគំរោងស្រាវជ្រាវមួយតែគួរអោយស្តាយមានស្ថានភាពខ្លះដែលសហគមន៍ត្រូវបានគេជញ្ជក់ផលប្រយោជន៍ដោយប្រើដំណើរការស្រាវជ្រាវ ។ តែផ្ទុយស្រឡះទៅវិញដោយសារគំរូដែលមិនមែនជាប្រជាធិបតេយ្យទូទៅនេះ "ការស្រាវជ្រាវដែលជាជំហានដំបូងនៃសហគមន៍" ត្រូវបានចាក់ឬក្នុងសហគមន៍ប្រើជាប្រយោជន៍របស់សហគមន៍ ហើយជាញឹកញាប់ជំរុញអោយមានការចូលរួមពីពលរដ្ឋគ្រប់ឋានៈ ។ ការស្រាវជ្រាវដែលមានមូលដ្ឋាននៅសហគមន៍នេះ មិនត្រឹមតែមានបំណងក្នុងការបង្កើនការយល់ដឹងប៉ុណ្ណោះទេ ថែមទាំងចង់ធានាថា ចំណេះដឹងនេះជាគ្រឹះដ៏មាំ ហើយមានប្រយោជន៍ខុសប្លែកផ្សេងៗពីគ្នានៅក្នុងពិភពលោកយើងនេះ ។

តើស្តាប់ទៅគួរអោយចាប់អារម្មណ៍ឬទេ?

- អ្នកឃើញផលប្រយោជន៍នៃការស្រាវជ្រាវ ប៉ុន្តែអ្នកចង់បង្កើនតួនាទី អោយកាន់តែសកម្មទៀតដើម្បីបញ្ជាក់អោយច្បាស់ថាការស្រាវជ្រាវនេះត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវតាមសីលធម៌ អ្នកបានបង្កើត ឬក៏ជាផ្នែកមួយនៃភាពជាដៃគូស្រាវជ្រាវ ប៉ុន្តែ តើអ្នកចង់ស្វែងរកយល់ថែមទៀតទៅក្នុងវិស័យស្រាវជ្រាវជំហានដំបូងនៃមណ្ឌលរបស់សហគមន៍ឬទេ?
- អ្នកប្រហែលជាធ្លាប់ឮ "Dutch" Science Shops" ប៉ុន្តែអ្នកមិនច្បាស់ណាស់ទេថា តើពួកវាអាចប្រើក្នុងសហរដ្ឋអាមេរិចឬសូម្បីតែនៅក្នុងទីក្រុងឡូវែលឬទេ ។

គំនិតខាងក្រោមអាចជួយអ្នកគិតអំពីលទ្ធភាពផ្សេងៗ

តើនឹងមានអ្វីកើតឡើង ប្រសិនបើសហរដ្ឋអាមេរិច មានបណ្តាញនៃមជ្ឈមណ្ឌលស្រាវជ្រាវសហគមន៍ជាច្រើន (ឬក៏ "កន្លែងតាំងគ្រឿងវិទ្យាសាស្ត្រ") ដែលមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យនានា ហើយរៀបចំ សហការ និងសង្ខេបការស្រាវជ្រាវនេះដើម្បីឆ្លើយតបទៅសំនួរដ៏ជាក់លាក់ដែលបានលើកឡើងសួរដោយក្រុមសហគមន៍?

ចាប់ផ្តើមដោយមើលនៅសាកលវិទ្យាល័យ

- តើផ្នែកនៃការស្រាវជ្រាវរបស់សាកលវិទ្យាល័យបានរៀបចំយ៉ាងដូចម្តេចខ្លះ?
- ធ្វើការយ៉ាងខ្ជាប់ខ្ជួនបង្កើតភាពជាដៃគូ ឬក៏ទាក់ទងនឹងភាពជាដៃគូដែលមានស្រាប់ហើយ ។

តើបញ្ហានេះអាចដំណើរការក្នុងសហគមន៍បានយ៉ាងណា?

- បង្កើននូវការទទួលស្គាល់ "សហគមន៍រួបរួម" មួយ
- យកកំលាំង និងធនធានក្នុងសហគមន៍ជាមូលដ្ឋាន
- ធ្វើអោយការទាក់ទងគ្នានៃដៃគូទាំងអស់ងាយស្រួលគ្រប់ដំណាក់កាលស្រាវជ្រាវ
- ផ្តល់ផលប្រយោជន៍ទៅវិញទៅមកសំរាប់ដៃគូទាំងអស់
- ចែកចាយលទ្ធផលនៃការរកឃើញទាំងអស់ដល់សហគមន៍

គន្លឹះថវិការផ្សេងថែមទៀត

- មជ្ឈមណ្ឌលថ្មីៗទាំងនេះអាចផ្តល់អោយក្រុមសហគមន៍ រដ្ឋាភិបាលក្នុងស្រុក និងអង្គការស្ម័គ្រចិត្ត នូវការគាំទ្រដែលពួកគេនឹងត្រូវការដើម្បីធ្វើកិច្ចការបន្ថែមនៅពេលដែលមានការកាត់បន្ថយថវិការ ។

- ពីព្រោះសិស្សធ្វើការស្រាវជ្រាវ ហើយនិងសរសេរអត្ថបទ ហើយគណៈសាស្ត្រាចារ្យ ជាអ្នកត្រួតត្រាមើល និងវាយតំលៃ

កិច្ចការរបស់ពួកគេ ដូច្នេះការចំណាយបន្ថែមគឺតិចបំផុត ។

- មានពេលខ្លះការស្រាវជ្រាវត្រូវបានបញ្ចុះបញ្ចូលដោយក្រសួងឧស្សាហកម្ម និងប្រភពនៃថវិការផ្សេងៗ ដូច្នេះមជ្ឈមណ្ឌល

សហគមន៏អាចជួយធ្វើអោយការចំណាយនេះមានតុល្យភាពបាន

- ឥឡូវនេះគឺអាចគេរកថវិកាជំនួយបានច្រើន សំរាប់ជំហានដំបូងនៃការស្រាវជ្រាវរបស់សហគមន៏

តើមជ្ឈ មណ្ឌលនានាដែលគេបង្កើតពីមុន%មកនៅក្នុងសហគមន៏មាននៅឯណា ខ៖ក្នុងសហរដ្ឋអាមេរិចនេះ?

- មានសហគមន៏គំរូខ្លះៗដែលមាននៅសេសសល់នៅឡើយដូចជា: វិទ្យាស្ថានផ្តល់ជំនួយឥតសំណង **Loka** បានចាប់ផ្តើម

ប្រមូលផ្តុំការសិក្សាស្រាវជ្រាវផ្អែកលើសសហគមន៏ ក្នុងសហរដ្ឋអាមេរិច និងកន្លែងផ្សេងទៀត អ្នកអាចឆែករកមើលបានតាម **www.loka.com.**

ចូរគិតថាតើគំរូការស្រាវ ជ្រាវ ដំបូងរបស់សហគមន៏អាចប្រើជាការនៅក្នុងឡូវែល បានទេ?

ឡូវែលគឺជាទីក្រុងដ៏ខុសប្លែកពីគេមួយ វាគឺជាផ្ទះនៃសហគមន៏ខ្មែរដ៏ធំជាងគេក្នុងសហរដ្ឋអាមេរិច ។ ឧទាហរណ៏មួយនៃ "ការស្រាវជ្រាវដំបូងនៃសហគមន៏" ដ៏ពិតប្រាកដនោះគឺ ភាពជាដៃគូខាងការគ្រប់គ្រងបរិដ្ឋានរបស់ប្រទេសអាស៊ីអគ្នេយ៏ **(Southeast Asian Environmental Justice Partnership)** គឺជាអ្នកដឹក នាំក្នុងសហគមន៏ខ្មែរ-ឡាវ សកម្មជនអ្នកប្រាជ្ញ ពីសាកលវិទ្យាល័យក្នុងស្រុក និងអ្នកផ្តល់ការថែរក្សាសុខភាព មកចូលរួមទាំងអស់គ្នា ដើម្បីស្តាប់និងដោះស្រាយបញ្ហាបរិដ្ឋាន ដូចជា បញ្ហាទឹក បញ្ហាបរិដ្ឋាន ថ្នាំលាបផ្ទះដែលមានជាតិសំណជាដើម ។

## ការបង្កើតចំណេះដឹងក្នុងការស្រាវជ្រាវ ភាពជាដៃគូ

ប៉ាស្កាល់ កាបានី **(Pascal Garbani)**

វិស័យចំបងពីរក្នុងការបង្កើតភាពជាដៃគូអោយបានជោគជ័យគឺ ចែករំលែកការឃើញដ៏ធម្មតានៃអនាគតមួយ ហើយនិងការបង្កើតចំណេះដឹង ។ ឧបសគ្គដ៏ធំមួយគឺធ្វើយ៉ាងណាដើម្បីច្រោះសំរាំងយកការពិតផ្សេងៗពីពលរដ្ឋ និងដើម្បីធ្វើអោយកិច្ចការនេះមានដំណើរការទៅមុខបានស្រួល ។

- ចូរយល់ស្របថា អ្នកឬក៏អង្គការដែលអ្នកជាតំណាំងបានបង្កើតនិន្នាការដ៏ខ្លាំងក្លាក្នុងរយៈប៉ុន្មានឆ្នាំមកហើយនេះអំពីអ្វីបង្កបង្កើតការសហប្រតិបត្តិការ និងចំណេះដឹងហើយយល់ស្របថាគំរូទាំងឡាយនេះប្រហែលជាត្រូវបានបង្កើតដោយខ្លួនឯង ដូច្នេះហើយ វាប្រហែលជាមានភាពលំអៀងបន្តិចបន្តួចនៅក្នុងចិត្តមិនខានឡើយ ។
- សហការជាមួយអ្នកណាដែលយើងត្រូវជៀសវាងមិនរួច ឱកាសគឺមនុស្សភាគច្រើនមានបំណងដំបូងគឺការបដិសេធ ភាពជាដៃគូមិនដូច ជាសហគមន៍ដែលប្រើពាក្យប្រៀបធៀបរបៀបកីឡាដែលថា ការងាររបស់ក្រុមដែលល្អមិនចាំបាច់មកពី សមាជិកច្រើនស្របតាមក្រឹតទេ ការងារក្រុមដែលល្អបានមកពីការទទួលយកភាពផ្សេងៗគ្នារបស់អ្នកដទៃទៀតធ្វើជាប្រភពនៃចំណេះដឹងថ្មីហើយឃើញកាន់តែធំធេង ហើយរឹតតែឥតខ្ចោះថែមទៀតផង ។
- ចូរប្រើពាក្យប្រៀបធៀបអោយបានច្រើន ដោយហៅអង្គភាពមួយដោយប្រើឈ្មោះផ្សេងមួយទៀត ឬដោយប្រើផ្នែកខ្លះជំនួសឈ្មោះទាំងមូល ប្រជាជនអាចពណ៌នាបទពិសោធន៍ផ្សេងៗ ឬគំនិតទាក់ទងដែលពិបាកបញ្ជាក់អោយច្បាស់ ។ ពាក្យប្រៀបធៀបផ្សេងៗអាចជួយសម្រួលទម្រង់ផ្លាស់ប្តូរ ដោយសារការធ្វើអ្វីអោយឃើញប្លែកៗ ពីភាពដែលយើងធ្លាប់ស្គាល់ ។ ពាក្យប្រៀបធៀបមួយណាដែលអ្នកប្រើ គឺមិនសំខាន់ប៉ុន្មានទេ តែការពិតវិញនោះគឺថា ក្រុមនេះបង្កើតពាក្យប្រៀបធៀបទាំងអស់គ្នា ដើម្បីបញ្ជាក់អោយច្បាស់ពីភាពមើលឃើញដូចគ្នាមួយនៃអនាគត ។
- ទទួលស្គាល់ថាអ្វីដែលបង្កបង្កើតចំណេះដឹង ហើយរបៀបដែលបង្កើតវាគឺជាការពិភាក្សាយូរមកហើយមួយដែលមិនទាន់បានដោះស្រាយនៅឡើយ ។ អ្នកខ្លះចាត់ទុកចំណេះដឹង គឺជាលទ្ធផលនៃដំណើរការរបស់ខួរក្បាល មានជាមូលដ្ឋានលើផ្នែកទ្រឹស្តី និងរូបមន្តនានាដូចជា អ្នករក្សាទុកហេតុផលជាដើម អ្នកខ្លះទៀតចាប់ទុកជាបទពិសោធន៍ខាងវិញ្ញាណ ដែលមានមូលដ្ឋានលើការយល់ឃើញដោយអារម្មណ៍ និងប្រផ្នូលផ្សេងៗ ជាប្រភពដំបូងនៃចំណេះដឹង គឺអ្នកពិសោធនិយម ។
- គេគិតថាគំរូបង្កើតចំណេះចេះដឹងនេះ បានត្រូវក្រុមហ៊ុនរបស់ជប៉ុនយកទៅប្រើប្រាស់បានមួយដង ហើយដើម្បីធ្វើអោយរីកចំរើនផ្នែកផលិតផល ដោយតម្រូវអោយមានសហប្រតិបត្តិការ (ធ្វើការរួមគ្នា) ពីក្រុមផ្នែកផ្សេងៗ ដែលមិនធ្លាប់ធ្វើការរួមគ្នា ហើយត្រូវបានគេសម្រឹតសម្រាំងរកបានការពិតផ្សេងៗពីគ្នាជាច្រើន ។ គំរូនេះបង្ហាញថាដើម្បីអោយក្រុមមួយបង្កើតចំណេះដឹង វាត្រូវការឱកាសជាច្រើនសារ ដើម្បីចែកចាយបទពិសោធន៍ផ្ទាល់ (ចំណេះកាត់ស្ទានយល់) មួយចូលក្នុងសង្គម ហើយនិងបញ្ចូលចំណេះដឹងនេះ ជាមួយគំរោងតាមទ្រឹស្តី (ចំណេះដឹងដែលចែងយ៉ាងច្បាស់លាស់) ។ សកម្មភាពធ្វើការជាមួយគ្នារវាងចំណេះខាងកាត់ស្ទានយល់ និងចំណេះដឹងដែលចែងយ៉ាងច្បាស់លាស់នេះ បាននាំមុខគេ ។

<u>ប្រភពផ្សេង%ៗ</u>

"ក្រុមហ៊ុនបង្កើតចំណេះដឹង" I. Nonaka and H. Takeuchi, Oxford University Press, 1995.

"ទ្រឹស្តីអង្គការដែលរស់រវើក" G. Morgan, Sage Publications, 1989.

"ទ្រឹស្តីអង្គការ" D. Pugh, Penguin Books, 1997.